# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 28-Jul-2011, 15:45
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សេចក្តីជូនដំណឹងអំពីការចូលរួមជាមួយនឹង ចម្លើយតបរបស់មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ទៅនឹង“សំណើបន្ទាន់របស់ មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី សុំអង្គជំនុំជម្រះសាលាដំបូងកែតម្រូវអនុស្សរណៈ:** E62/3/10 (**អនុស្សរណៈចាស់លេខ** E106)

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រំ ផល្លា

ផ្ញើជូន៖

**ក្រុមមេធាវីការពារក្តីទាំងអស់**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**

ពេជ អង្គ

Elisabeth SIMONNEAU FORT

# សេចក្តីជូនដំណឹងអំពីការចូលរួម

១. នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ មធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ (មេធាវីការពារក្តី លោកស្រី អៀង ធីរិទ្ធ) បានដាក់ការជំទាស់ទៅនឹងសេចក្តីប្រកាសរបស់អង្គជំនុំជម្រះដែលនឹងដាក់របាយការណ៍អ្នកជំនាញដែលរៀបចំឡើងដោយលោកសាស្ត្រាចារ្យ John Campbell ("របាយការណ៍") ទៅក្នុងផ្នែកសម្ងាត់នៃសំណុំរឿង[1]។ នៅថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ មេធាវីការពារក្តីលោក នួន ជា ("មេធាវីការពារក្តី") បានជូនដំណឹងអំពីការចូលរួមនឹងការជំទាស់នោះ[2]។ នៅថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានផ្ញើអនុស្សារណៈមួយនិយាយអំពីបញ្ហានេះ[3]។ នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១ មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ "សំណើបន្ទាន់សុំអង្គជំនុំជម្រះសាលាដំបូងកែតម្រូវអនុស្សារណៈ E62/3/10" ដែលបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១ ("សំណើបន្ទាន់របស់ដើមបណ្តឹងរដ្ឋប្បវេណី")[4]។ នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ បានដាក់ចម្លើយតបទៅនឹង"សំណើបន្ទាន់របស់មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី សុំអង្គជំនុំជម្រះសាលាដំបូងកែតម្រូវអនុស្សារណៈ E62/3/10 (អនុស្សារណៈចាស់លេខ E106)" ("ចម្លើយតបរបស់មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ")[5]។

---

[1] ឯកសារលេខ **E-62/3/7** "សេចក្តីជំទាស់របស់ក្រុមមេធាវីការពារក្តីទៅនឹងការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការដាក់របាយការណ៍វេជ្ជសាស្ត្ររបស់វេជ្ជបណ្ឌិត Campbell ទៅក្នុងផ្នែក "សម្ងាត់" នៃសំណុំរឿង" ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១, ERN 00710705–00710710។

[2] ឯកសារលេខ **E62/3/8**, ការជូនដំណឹងរបស់ នួន ជា អំពីការចូលរួមជាមួយនឹងសេចក្តីជំទាស់របស់ក្រុមមេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ទៅនឹងការដាក់របាយការណ៍សម្បទា ទៅក្នុងផ្នែក "សម្ងាត់" នៃសំណុំរឿង, ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០១១, ERN 00711960-00711961។

[3] ឯកសារលេខ **E-62/3/10** អនុស្សារណៈពីអង្គជំនុំជម្រះសាលាដំបូងជូនមេធាវីការពារក្តីដែលជាភាគី, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១, ERN 00711926-00711927។

[4] ឯកសារលេខ E62/3/10/1 មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី "សំណើបន្ទាន់សុំអង្គជំនុំជម្រះសាលាដំបូងកែតម្រូវអនុស្សារណៈ E62/3/10 (អនុស្សារណៈចាស់លេខ E106)", ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១ ERN 007165573-00716579។

[5] ឯកសារលេខ **E62/3/10/2** ចម្លើយតបរបស់មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ទៅនឹង"សំណើបន្ទាន់របស់ មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី សុំអង្គជំនុំជម្រះសាលាដំបូងកែតម្រូវអនុស្សារណៈ E62/3/10 (អនុស្សារណៈចាស់លេខ E106)", ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, ERN 00718383-00718388។

២. សម្រាប់ហេតុផលជាច្រើន និងផ្អែកលើអំណះអំណាងជាច្រើន[6] មេធាវីការពារក្តី លោកស្រីអៀង ធីរិទ្ធ បានស្នើឲ្យអង្គជំនុំជម្រះ “ (i) សម្រេចមិនទទួលយកសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ii)ឬ ជាជម្រើសផ្សេងទៀត បដិសេធសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងស្រុង[7]។ មេធាវីការពារក្តីលោក នួន ជា សូមទទួលយកការកត់សម្គាល់ និងអំណះអំណាងទាំងស្រុង *mutatis mutandis*, នៅក្នុងចម្លើយតប របស់មេធាវីការពារក្តី លោកស្រី អៀង ធីរិទ្ធ ទៅនឹងសំណើបន្ទាន់របស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងចូលរួមជាមួយ មេធាវីការពារក្តី លោកស្រី អៀង ធីរិទ្ធ ក្នុងការសុំឲ្យដោះស្រាយសំណើជាក់លាក់ដែលបានស្នើ។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Michel PESTMAN & Victor KOPPE

---

[6] ដូចខាងលើ កថាខណ្ឌ ៥-២១។

[7] ដូចខាងលើ កថាខណ្ឌ ២២។